# សមធម៌នៃយន្តការរេដបូក និងការប្រែប្រួលអាកាសធាតុ

## ឯកសារណែនាំសម្រាប់អ្នកសម្របសម្រួលសហគមន៍



### សំណួរ និង ចម្លើយ

USAID FROM THE AMERICAN PEOPLE

Norad

RECOFTC THE CENTER FOR PEOPLE AND FORESTS

សមធម៌នៃយន្តការរេដបូក និងការប្រែប្រួលអាកាសធាតុ
ឯកសារណែនាំសម្រាប់អ្នកសម្របសម្រួលសហគមន៍
សំណួរ និងចម្លើយ

© រក្សាសិទ្ធដោយ RECOFTC ខែវិច្ឆិកា ឆ្នាំ២០១៤
បាងកក ព្រះរាជាណាចក្រថៃ

រាល់រូបភាពដែលប្រើប្រាស់ក្នុងរបាយការណ៍នេះជាកម្មសិទ្ធិរបស់ RECOFTC

ការបោះពុម្ព និងការផលិតឯកសារនេះឡើងវិញ សម្រាប់ការអប់រំ និងគោលបំណងទាំងឡាយណាដែលមិនសំដៅរកប្រាក់ចំណេញ អាចធ្វើបានដោយមិនចាំបាច់សុំការអនុញ្ញាតិជាលាយល័ក្ខអក្សរ ពីម្ចាស់កម្មសិទ្ធិជាមុនឡើយ តែអ្នកប្រើប្រាស់ត្រូវបញ្ជាក់ពីប្រភពឯកសារ និងអ្នករៀបរៀងឲ្យបានច្បាស់។ រាល់ការបោះពុម្ពឯកសារនេះឡើងវិញសម្រាប់ការលក់ដូរ និងប្រាក់ចំណេញ មិនត្រូវបានអនុញ្ញាតិឡើយ លើកលែងតែមានការព្រមព្រៀងជាលាយល័ក្ខអក្សរជាមុនពីម្ចាស់កម្មសិទ្ធិ។

ឯកសារនេះត្រូវបានរៀបរៀងដោយអង្គការរីខូហ្វ ក្រោមគម្រោងកសាងសមត្ថភាពសហគមន៍ស្តីពីរេដបូក ដែលទទួលជំនួយថវិកាពី ទីភ្នាក់ងារន័រវេសសម្រាប់កិច្ចសហប្រតិបត្តការអភិវឌ្ឍ (NORAD) និងកម្មវិធីសមធម៌ និងការពង្រឹងបណ្តាញនៅមូលដ្ឋាន (កម្មវិធី Green Mekong) ដែលទទួលជំនួយថវិកាពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID)។ រាល់ទស្សនៈ និងគំនិតទាំងឡាយនៅក្នុងឯកសារនេះ មិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ រីខូហ្វ-មជ្ឈមណ្ឌលសម្រាប់មុនស្ស និងព្រៃឈើ (RECOFTC -The Center for People and Forests), NORAD និង USAID ទេ។

# សេចក្តីថ្លែងអំណរគុណ

រីខូហ្វ  សូមថ្លែងអំណរគុណដល់ទីភ្នាក់ងារន័រវេសសម្រាប់កិច្ចសហប្រតិបត្តការអភិវឌ្ឍ ដែលបានគាំទ្រថវិកាដល់គម្រោងកសាងសមត្ថភាពសហគមន៍ស្តីពីរេដបូក  និងទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ ដែលបានគាំទ្រថវិកាដល់ កម្មវិធី Green Mekong ។

# គោលបំណង

សៀវភៅសំនួរ និងចម្លើយនេះរៀបចំដោយគម្រោងកសាងសមត្ថភាពសហគមន៍ស្តីពីរេដបូកសម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក និង គម្រោងសមធម៌ និងការពង្រឹងបណ្តាញនៅមូលដ្ឋាន ( កម្មវិធី Green Mekong ) ។ សៀវភៅនេះ មានគោលបំណងជួយដល់អ្នកសម្របសម្រួលសហគមន៍ ដែលកំពុងធ្វើការងារកសាងសមត្ថភាពដើម្បីលើកកម្ពស់សមធម៌សង្គម នៅក្នុងបរិបទនៃការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ជាពិសេសលើការកាត់បន្ថយការបញ្ចេញឧស្ម័នដែលបណ្តាលមកពីបាត់បង់ និងរេចរឹលព្រៃឈើ ។ សៀវភៅនេះអាចជាឯកសារយោងសម្រាប់អ្នកពាក់ព័ន្ធទាំងអស់ដែលធ្វើការនៅថ្នាក់ខេត្ត និងថ្នាក់ស្រុកដូចជាមន្ត្រីជំនាញព្រៃឈើ ដែលធ្លាប់ចូលរួមក្នុងបណ្តាញរៀនសូត្រស្តីពីការពង្រឹងសមធម៌ នៃការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងព្រៃឈើ ទាំងនៅថ្នាក់មូលដ្ឋាន និងថ្នាក់តំបន់ ។

មានឯកសារជាច្រើនស្តីពីរេដបូក និងសមធម៌នៅក្នុងដំណើរការរេដបូកត្រូវបានបោះពុម្ពរួចមកហើយ ប៉ុន្តែភាគច្រើន មិនសូវមានឯកសារស្តីពីសមធម៌នៃរេដបូក ដែលមានភាពសាមញ្ញ និងងាយយល់សម្រាប់អ្នកពាក់ព័ន្ធនៅថ្នាក់សហគមន៍ប្រើប្រាស់នោះទេ ។ នេះជាភាពប្រឈមមួយដល់អ្នកពាក់ព័ន្ធនៅសហគមន៍ ក្នុងការប្រើប្រាស់ ព័ត៌មាន និងទិន្នន័យ ដែលមានក្នុងឯកសារទាំងនោះ ក្នុងកិច្ចប្រឹងប្រែងពង្រឹងសមធម៌នៅមូលដ្ឋានរបស់ពួកគេ ។ សមធម៌ជាទស្សនទានមួយដែលពិបាកយល់ និងមានភាពស្មុគស្មាញក្នុងការបកស្រាយ ហេតុនេះការពន្យល់បែបសាមញ្ញ ងាយយល់ ផ្សារភ្ជាប់នឹងបទពិសោធន៍នៅសហគមន៍គឺជាការចាំបាច់ ។ ដោយសារសមត្ថភាពអ្នកពាក់ព័ន្ធនៅមូលដ្ឋាន រួមទាំងសង្គមស៊ីវិល ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាលផងនៅមានកម្រិត ធ្វើឲ្យពួកគេពិបាកក្នុងការបង្ហាញបានក្បោះក្បាយនូវចក្ខុវិស័យ និង ចំណាប់អារម្មណ៍របស់ពួកគេទៅដល់អ្នករៀបចំគោលនយោបាយ ព្រមទាំងអាចឲ្យពួកបកស្រាយខុសនូវទស្សនទានទាំងនេះក្នុងការងាររបស់ខ្លួន ។ សៀវភៅសំណួរ និងចម្លើយនេះ មានគោលបំណងផ្តល់នូវការពន្យល់បែបសាមញ្ញលើសមាសធាតុ និងទស្សនទានមួយចំនួននៃសមធម៌សង្គម នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ រេដបូក និងការគ្រប់គ្រងព្រៃឈើ ។

---

1 រេដ បូ ក សំដៅលើកត្តាមួយចំនួនលើសពីការបាត់បង់ និងរេចរឹលព្រៃឈើ រួមមានការអភិរក្ស ការបង្កើនកម្រិតស្តុកកាបូនព្រៃឈើ និងការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព ។

# មាតិកានៃសៀវភៅ

សៀវភៅនេះរួមមានសំណួរ និង ចម្លើយចំនួន១០។ សំណួរបានរៀបចំឡើងដើម្បីឆ្លើយតបនឹងតម្រូវការកសាងសមត្ថភាពសម្រាប់អ្នកសម្របសម្រួលសហគមន៍ ដោយផ្តោតលើមូលដ្ឋានគ្រឹះនៃសមធម៌សង្គម នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងព្រៃឈើ។ ជាមួយគ្នានេះដែរខ្លឹមសារសំណួ និងចម្លើយទាំងនេះក៏ជួយជម្រុញលើកទឹកចិត្តដល់អ្នកសម្របសម្រួលសហគមន៍ក្នុងការពង្រឹងសមធម៌ និងការចូលរួមនៅក្នុងសកម្មភាពនានានៃរេដបូក និងការប្រែប្រួលអាកាសធាតុផងដែរ។ សំណួរត្រូវបានរៀបចំដូចខាងក្រោមនេះ៖

**ផ្នែកទី១:មូលដ្ឋានគ្រឹះ** ពន្យល់ពីទស្សនទាននៃសមធម៌សង្គមប្រភេទ សមធម៌ និងភាពខុសគ្នារវាងសមធម៌ និងសមភាព នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ រេដបូក និងការគ្រប់គ្រងព្រៃឈើ។

**ផ្នែកទី២:** សមធម៌នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ រេដបូក និងការគ្រប់គ្រងព្រៃឈើ ផ្តោតលើការវិវត្តន៍នៃទស្សនទាន សមធម៌នៅក្នុងវិស័យព្រៃឈើជារួម ព្រមទាំងពិភាក្សាពីមូលហេតុក្នុងការពង្រឹងសមធម៌នៅក្នុងបរិបទនៃ ការប្រែប្រួលអាកាសធាតុ រេដបូក និងការគ្រប់គ្រងព្រៃឈើ។

**ផ្នែកទី៣:** គោលនយោបាយ និង ភាពប្រឈមនានា ផ្នែកនេះពន្យល់ពីឯកសារគោលនយោបាយអន្តរជាតិនានាដែលមានគោលដៅជម្រុញសមធម៌នៅក្នុងការប្រែប្រួលអាកាសធាតុ និងរេដបូក។ ផ្នែកនេះក៏លើកឡើងពីភាពប្រឈមនានាលើការពង្រឹងសមធម៌ ដែលកើតមានឡើងនៅថ្នាក់មូលដ្ឋានផងដែរ។

**ផ្នែកទី៤:** ការអភិវឌ្ឍសមត្ថភាពដើម្បីលើកកម្ពស់សមធម៌ ផ្នែកនេះផ្តោតលើតម្រូវការ និងចំណុចសំខាន់ៗក្នុងការ អភិវឌ្ឍសមត្ថភាពនៅថ្នាក់មូលដ្ឋានដើម្បីលើកកម្ពស់ និងធ្វើឲ្យប្រសើរឡើងនូវសមធម៌សង្គម។ ផ្នែកនេះពិភាក្សាផងដែរពី លក្ខណៈវិនិច្ឆ័យ និងសូចនាករ សម្រាប់ត្រួតពិនិត្យប្រសិទ្ធិភាពនៃការរួមបញ្ចូលគោលការណ៍គ្រឹះនៃសមធម៌ ទៅក្នុងយន្តការរេដបូក និងការប្រែប្រួលអាកាសធាតុ។ លើសពីនេះទៀតផ្នែកនេះក៏បានពណ៌នាពីការរួមចំណែករបស់គម្រោងថ្នាក់តំបន់ពីរ (គម្រោងកសាងសមត្ថភាពស្តីពីរេដបូក និងកម្មវិធី Green Mekong) របស់រីខូហ្វ ក្នុងកិច្ចប្រឹងប្រែងលើកកម្ពស់សមធម៌ក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងព្រៃឈើ។

# សំណួរសំខាន់ៗទាំង ១០





## ផ្នែកទី១ - មូលដ្ឋានគ្រឹះនៃសមធម៌

**ស.១** តើសមធម៌មានន័យដូចម្តេច ហើយ សមធម៌ និងសមភាព ខុសគ្នាដូចម្តេច ?

**ស.២** តើសមធម៌មានទិដ្ឋភាពសំខាន់ៗអ្វីខ្លះ ?

## ផ្នែកទី២ - សមធម៌នៅក្នុងបរិបទនៃ ការប្រែប្រួលអាកាសធាតុ រេដបូក និងការគ្រប់គ្រងព្រៃឈើ

**ស.៣** តើអ្វីខ្លះជាមូលដ្ឋានគ្រឹះក្នុងការលើកកម្ពស់សមធម៌នៅក្នុងការកាត់បន្ថយការប្រែប្រួលអាកាធាតុតាមរយៈព្រៃឈើ ?

**ស.៤** តើបញ្ហាសមធម៌សំខាន់ៗមានអ្វីខ្លះ នៅក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុតាមរយៈព្រៃឈើ ?

**ស.៥** តើអ្នកពាក់ព័ន្ធនៅមូលដ្ឋានអាចរងឥទ្ធិពលអ្វីខ្លះ ពីការកាត់បន្ថយការប្រែប្រួលអាកាធាតុតាមរយៈព្រៃឈើ ប្រសិនបើគ្មានសមធម៌ ?





## ផ្នែកទី៣ - ឯកសារគោលនយោបាយ និងភាពប្រឈមនានាក្នុងការលើកកម្ពស់សមធម៌នៅក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុតាមរយៈព្រៃឈើ នៅថ្នាក់មូលដ្ឋាន

**ស.៦** តើមានក្របខ័ណ្ឌ និងគោលនយោបាយអន្តរជាតិអ្វីខ្លះ ដែលលើកកម្ពស់សមធម៌នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ រេដបូក និងការគ្រប់គ្រងព្រៃឈើ ?

**ស.៧** តើមានភាពប្រឈមអ្វីខ្លះក្នុងការធានាឲ្យមានសមធម៌ក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុតាមរយៈព្រៃឈើនៅថ្នាក់មូលដ្ឋាន ?

## ផ្នែកទី៤ - ការអភិវឌ្ឍសមត្ថភាពដើម្បីលើកកម្ពស់សមធម៌នៅថ្នាក់មូលដ្ឋាន

**ស.៨** តើអ្នកសម្របសម្រួលមូលដ្ឋានមានតួនាទីអ្វីខ្លះដើម្បីលើកកម្ពស់សមធម៌នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ និងរេដបូក ?

**ស.១០** តើ រ៉ិខូហ្វ មានតួនាទីអ្វីខ្លះក្នុងការលើកកម្ពស់សមធម៌ក្នុងការកាត់បន្ថយការប្រែប្រួលអាកាធាតុតាមរយៈព្រៃឈើ ?

**ស.៩** តើមានលក្ខណៈវិនិច្ឆ័យ និងសូចនាករអ្វីខ្លះដើម្បីត្រួតពិនិត្យសមធម៌ នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ រេដបូក និងការគ្រប់គ្រងព្រៃឈើ ?



# ផ្នែកទី១ - មូលដ្ឋានគ្រឹះនៃសមធម៌

# ស.១

## តើសមធម៌មានន័យដូចម្ដេច ហើយសមធម៌ និងសមភាពខុសគ្នាដូចម្ដេច?

សមធម៌សំដៅលើស្ថានភាពដែលបុគ្គលគ្រប់រូបទទួលបាន សិទ្ធិ ឱកាស និង ធនធានចាំបាច់ដើម្បីសម្រេចបានគោលដៅរបស់ពួកគេ។ នេះផ្អែកលើទស្សនដែលយល់ថា មនុស្សម្នាក់ៗ ជាអ្នកកំណត់ជោគវាសនារបស់គេដោយខ្លួនឯង ពោលគឺមិនមែនដោយសារឥទ្ធិពលនៃបរិយាកាសជុំវិញ និងលក្ខ័ណ្ឌនានាដែលអាចមិនមានភាពយុត្តិធម៌សម្រាប់ពួកគេនោះទេ។ សមធម៌ក៏សំដៅលើការបែងចែកធនធានដល់បុគ្គលម្នាក់ៗក្នុងចំណែកមួយដ៏សមរម្យ (fair share) តាមរយៈដំណើរការបែងចែកដែលមិនលំអៀង និងមានយុត្តិធម៌។

ដូចនេះយើងអាចឲ្យនិយមន័យសមធម៌ថាជា *ភាពសមរម្យនៃការឲ្យតំលៃលើអ្នកពាក់ព័ន្ធទាំងអស់ នៅក្នុងដំណើរការរៀបចំ និងអនុវត្តន៍គោលនយោបាយ ក៏ដូចជាភាពសមរម្យក្នុងការបែងចែកធនធាន និងផលប្រយោជន៍ ដែលទទួលបានពីគោលនយោបាយនេះក្នុងចំណោមអ្នកពាក់ព័ន្ធទាំងនេះ។ ដំណើរការនេះត្រូវធ្វើឡើងដោយផ្អែកលើគោលការណ៍ជាមូលដ្ឋានមួយចំនួនដែលអ្នកទាំងអស់បានព្រមព្រៀងគ្នា។*

សមធម៌មានទំនាក់ទំនងទៅនឹងគោលការណ៍សមភាព ដែលមានន័យថាបុគ្គលគ្រប់រូបមានសិទ្ធិស្មើគ្នា។ ជារឿយៗសមធម៌ ត្រូវបានគេយល់ច្រឡំថាមានន័យដូចគ្នានឹងសមភាពដែរ ប៉ុន្តែពាក្យទាំងពីរនេះមានន័យខុសគ្នា។ សមភាពសំដៅលើការចាត់ទុកបុគ្គលគ្រប់រូបដូចៗគ្នាដោយមិនគិត ឋានៈ តួនាទី និងស្ថានភាពរបស់ពួកគេឡើយ។ ការចាត់ទុកបុគ្គលគ្រប់រូបថាដូចគ្នាបែបនេះមិនប្រាកដថាអាចទទួលបានលទ្ធផលមួយដែលសមរម្យ និងយុត្តិធម៌នោះទេ។ ដូចនេះការប្រើវិធានសមភាពអាចទទួលបានលទ្ធផលមួយ ដែលយុត្តិធម៌ក្នុងករណីដែលបុគ្គលគ្រប់រូបមានតម្រូវការ និងស្ថានភាពលទ្ធភាពដូចគ្នា។ ដោយឡែកសមធម៌វិញ គឺការទទួលស្គាល់ថាបុគ្គលគ្រប់រូបមិនមែនមានតួនាទីដូចគ្នានោះទេ ហេតុនេះការចាត់ទុកថាអ្នកទាំងអស់គ្នាមានលទ្ធភាពដូចគ្នាអាចធ្វើឲ្យបុគ្គលមួយចំនួនមិនអាចប្រកួតប្រជែងដោយស្មើភាពបានទេជាពិសេសនៅពេលដែលពួកគេត្រូវឆ្លើយតបនឹងលក្ខខ័ណ្ឌប្រកួតប្រជែងមួយចំនួនដែលលើសពីលទ្ធភាពរបស់គេ។

សមធម៌ មានគោលដៅលុបបំបាត់ឧបសគ្គដែលរារាំងលទ្ធភាព និងសក្ដានុពលរបស់បុគ្គលម្នាក់ៗ។ វិធីសាស្ត្រដែលផ្ដោតលើសមធម៌ ជួយកំណត់កត្តាដែលធ្វើឲ្យបុគ្គលម្នាក់ៗមានលទ្ធភាពខុសៗពីគ្នាដើម្បីស្វែងរកវិធានការដោះស្រាយបញ្ហាទាំងនេះ។

វិសមធម៌ កើតឡើងដោយសារភាពរើសអើងចំពោះក្រុមមនុស្សណាមួយនៅក្នុងសង្គមទៅលើភេទ ជនជាតិ សាសនា និងពិការភាពជាដើម។ ភាពរើសអើងទាំងនេះនឹងនាំឲ្យបុគ្គល ឬក្រុមខ្លះបាត់បង់ឱកាសប្រើប្រាស់សិទ្ធិរបស់ពួកគេ ក្នុងការទទួលបានធនធានដែលជាចំណែករបស់គេ ហើយដែលធ្វើឲ្យធនធាននេះធ្លាក់ទៅសមាជិកផ្សេងទៀតទៅវិញ។ វិសមធម៌អាចកើតឡើងចំពោះបុគ្គលដែលរស់នៅក្នុងភាពក្រីក្រ អ្នករស់នៅតំបន់ដាច់ស្រយាលខ្លាំង មិនបានទទួលព័ត៌មាន និងសេវាផ្សេងៗ និងតំបន់ដែលរងគ្រោះដោយសារគ្រោះធម្មជាតិជាដើម។ វិសមធម៌អាចកើតមានឡើងនៅគ្រប់កម្រិតពោលគឺទាំងថ្នាក់តំបន់ (ប្រទេស និងប្រទេស) រហូតដល់ថ្នាក់បុគ្គលក្នុងចំណោមសមាជិកនៃសហគមន៍មួយ។

# ស.២

## តើសមធម៌មានទិដ្ឋភាពសំខាន់ៗអ្វីខ្លះ?

សមធម៌មានទិដ្ឋភាពសំខាន់ៗបីគឺ ការចែករំលែក នីតិវិធី និងបរិបទ៖

**សមធម៌នៃការបែងចែក៖** ទាក់ទងនឹងភាពសមរម្យក្នុងការបែងចែកផលប្រយោជន៍ តំលៃវិភាគទាន ការចូលរួម និងហានិភ័យ ក្នុងចំណោមអ្នកពាក់ព័ន្ធ ដែលជាលទ្ធផលនៃការដាក់ចេញគោលនយោបាយ ឬនីតិវិធីគ្រប់គ្រងធនធានធម្មជាតិ។ ជាទូទៅសមធម៌នៃការចែករំលែក បង្ហាញពីទិដ្ឋភាពសេដ្ឋកិច្ចនៃសមធម៌។

**សមធម៌តាមនីតិវិធី៖** សំដៅលើភាពសមរម្យនៃដំណើរការធ្វើសេចក្ដីសម្រេចចិត្ត ការបែងចែកធនធាន និងការដោះស្រាយទំនាស់។ សមធម៌តាមនីតិវិធី គិតគូពីភាពជាតំណាង ការទទួលស្គាល់/ការរួមបញ្ចូលគ្រប់សមាជិកក្នុងសង្គម ការចូលរួម និងការបញ្ចេញមតិយោបល់។ សមធម៌តាមនីតិវិធី ក៏សំដៅលើការអនុវត្តប្រកបដោយយុត្តិធម៌ នូវនីតិវិធី ឧទាហរណ៍៖ គ្មានអំពើពុករលួយ គ្មានបក្សពួកជាដើម។

**សមធ៌មតាមបរិបទ៖** ផ្សារភ្ជាប់នូវទិដ្ឋភាពសមធម៌ទាំងពីរខាងលើ ដោយ ពិនិត្យទៅលើលក្ខ័ណ្ឌសង្គម សេដ្ឋកិច្ច និងនយោបាយ ដែលកំណត់លទ្ធភាពរបស់អ្នកពាក់ព័ន្ធចូលរួមដំណើរការនីតិវិធី និងដែលមានឥទ្ធិពលលើលទ្ធផលនៃការបែងចែក។ សមធម៌តាមបរិបទគិតគូពី សមត្ថភាពបុគ្គល (ដូចជា ការអប់រំ ឥទ្ធិពលនយោបាយ) ការទទួលបានធនធាន (ធនធានធម្មជាតិ ទ្រព្យសម្បត្តិ កំលាំងពលកម្ម បណ្ដាញទីផ្សារជាដើម) និងអំណាច (ដើម្បីបង្កើន និងការពារសិទ្ធិលើការទទួលបានធនធានធម្មជាតិរបស់គេ)។

ទិដ្ឋភាពសមធម៌ទាំងបីនេះ មានទំនាក់ទំនងគ្នាទៅវិញទៅមក ដូចនេះប្រសិនបើខ្វះទិដ្ឋភាពណាមួយវានឹងប៉ះពាល់ដល់លទ្ធផលនៃការពង្រឹងសមធម៌។ ឧទាហរណ៍៖ កត្តាសមត្ថភាព ការប្រើប្រាស់ធនធាន និងអំណាច អាចមានឥទ្ធិពលយ៉ាងខ្លាំងលើទិដ្ឋភាព សមធម៌តាមនីតិវិធី និងសមធម៌នៃការចែករំលែក។ ដូចគ្នាដែរការអនុវត្ត គោលការណ៍ សេរីភាពនៃការទទួលបានព័ត៌មាន និងការព្រមព្រៀងជាមុននឹងមិនអាចជួយសហគមន៍ឲ្យការពារផលប្រយោជន៍របស់ពួកគេបានទេ ក្នុងស្ថានភាពដែលពួកគេមិនមានព័ត៌មាន ពេលវេលា និងបទពិសោធន៍គ្រប់គ្រាន់ ដើម្បីចូលរួម។


Xayalath
Phonesavanh
Scotch Brand Tape
3M



# ផ្នែកទី២ - សមធម៌នៅក្នុងបរិបទនៃការប្រែប្រួល អាកាសធាតុ រេដបូក និងការគ្រប់គ្រងព្រៃឈើ

# ស.៣

## តើអ្វីខ្លះជាមូលដ្ឋានគ្រឹះក្នុងការលើកកម្ពស់សមធម៌នៅក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុតាមរយៈព្រៃឈើ ?

នៅក្នុងវិស័យអភិវឌ្ឍន៍ ក៏ដូចជាវិស័យព្រៃឈើដែរ សមធម៌មិនមែនជាទស្សនទានថ្មីនោះទេ។ ការជជែកពិភាក្សាពីមូលហេតុ និងវិធីសាស្រ្តពង្រឹងសមធម៌ក្នុងវិស័យព្រៃឈើបានវិវត្តន៍ទៅតាមពេលវេលា។ ចាប់ផ្តើមពីការអនុវត្តវិធីសាស្រ្តគ្រប់គ្រងព្រៃឈើដោយមានការចូលរួម (ដូចជា ការគ្រប់គ្រងព្រៃឈើដោយមានការចូលរួមពីសហគមន៍ ការគ្រប់គ្រងសហគមន៍ព្រៃឈើ ការគ្រប់គ្រងព្រៃឈើរួមគ្នា ការគ្រប់គ្រងព្រៃឈើដោយមានការចូលរួម ព្រៃឈើភូមិ។ល។) ការផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើសមធម៌ក្នុងវស័យព្រៃឈើនៅមានដែនកំណត់នៅឡើយទៅលើ ភាពសមរម្យ និងយុត្តិធម៌សង្គមក្នុងការបែងចែកផលប្រយោជន៍( សមធម៌នៃការបែងចែក )។ បន្ទាប់មកនៅពេលដែលមានការនុវត្តវិធីសាស្រ្តតស៊ូមតិដោយផ្អែកលើគោលការណ៍សិទ្ធិមនុស្ស ទស្សនទានសមធម៌ បានវិវត្តន៍មួយកម្រិតទៀតដោយផ្តោតលើការពង្រឹងអំណាច និងអភិវឌ្ឍសមត្ថភាពសហគមន៍ និងបុគ្គល ដើម្បីឲ្យពួកគេអាចចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត (សមធម៌តាមនីតិវិធី) និងធានាសិទ្ធិទទួលបានធនធាន និងលទ្ធភាពដើម្បីការពារសិទ្ធិនេះ (សមធម៌តាមបរិបទ)។

ដូចនេះការពង្រឹងសមធម៌ក្នុងវិស័យព្រៃឈើគឺជាគោលការណ៍គ្រឹះដើម្បីធានាបាននូវភាពសមរម្យក្នុងការបែងចែកការទទួលខុសត្រូវ តំលៃវិភាគទាន និងផលប្រយោជន៍ ក្នុងចំណោមបុគ្គលគ្រប់រូបដែលចូលរួមគ្រប់គ្រង និងអាស្រ័យលើធនធានព្រៃឈើ ដែលកត្តានេះនឹងជួយឲ្យមាននិរន្តរភាពនៃផលិតផល និងសេវាកម្មព្រៃឈើ សម្រាប់ការប្រកបរបរចិញ្ចឹមជីវិត។ ការសម្រេចលទ្ធផលនេះទាមទារនូវការរួមបញ្ចូលនូវទិដ្ឋភាពទាំងបីនៃសមធម៌ ក្នុងការគ្រប់គ្រងព្រៃឈើ។ ការខ្វះទិដ្ឋភាពណាមួយអាចធ្វើឲ្យប៉ះពាល់ដល់ចំណូលអប្បរមារបស់សមាជិកសហគមន៍សម្រាប់ទ្រទ្រង់ការចិញ្ចឹមជីវិតពួកគេ។ ជាងនេះទៀតការដែលអ្នកពាក់ព័ន្ធមិនទទួលបានសិទ្ធិស្មើគ្នាក្នុងការសម្រេចចិត្តលើការគ្រប់គ្រង និងប្រើប្រាស់ធនធានព្រៃឈើនឹងមានឥទ្ធិពលខ្លាំងលើ សមធម៌តាមនីតិវិធី និងសមធម៌នៃការបែងចែក ដែលនាំឲ្យមានវិសមធម៌។ បញ្ហានេះអាចកាត់បន្ថយ និងជៀសវាងបាន ប្រសិនបើមានការគាំទ្រដោយផ្ទាល់ដល់អ្នកក្របំផុត និងក្រុមជនងាយរងគ្រោះនៅក្នុងសហគមន៍ (សមធម៌តាមបរិបទ) និងជួយពួកគេឲ្យទទួលផលប្រយោជន៍បានច្រើនជាងមុន (សមធម៌នៃការចែករំលែក) ដោយផ្តល់ឱកាសឲ្យពួកគេចូលរួមធ្វើសេចក្តីសម្រេចចិត្ត (សមធម៌តាមនីតិវិធី) ដូចមានក្នុងករណីសិក្សាពីប្រទេសនេប៉ាល់ (សូមអានប្រអប់ទី១)។

**ប្រអប់ទី១៖ សមធម៌នៃការបែងចែក សមធម៌តាមនីតិវិធី និងសមធម៌តាមបរិបទ ក្នុងការគ្រប់គ្រងសហគមន៍ព្រៃឈើ**

សហគមន៍ព្រៃឈើនៅប្រទេសនេប៉ាល់បានផ្ដល់ជាឧទាហរណ៍ពីអន្តរកម្មរវាងសមធម៌នៃការចែករំលែកសមធម៌តាមនីតិវិធី និងសមធម៌តាមបរិបទ។

សហគមន៍ព្រៃឈើបានចាប់ផ្ដើមអនុវត្តន៍នៅកំឡុងទសវត្សឆ្នាំ១៩៧០ ដោយមានគោលបំណងសំខាន់ក្នុងការស្ដារព្រៃឈើឡើងវិញ។ ដើម្បីសម្រេចគោលដៅនេះ យុទ្ធសាស្ត្រមួយចំនួនត្រូវបានដាក់ចេញ ដែលក្នុងនោះមាន ការហាមឃាត់ការដកហូតផលព្រៃឈើរបស់សមាជិកសហគមន៍ ដើម្បីទុកលទ្ធភាពឲ្យព្រៃដុះលូតលាស់ឡើងវិញ។ ប៉ុន្តែវិធានការនេះបានធ្វើឲ្យសមាជិកសហគមន៍ខ្លះដែលពឹងអាស្រ័យផលខ្លាំងលើការប្រមូលធនធានព្រៃឈើបានបាត់បង់ប្រាក់ចំណូលរបស់ពួកគេ ដោយសារពួកគេពុំមានដីព្រៃឯកជនផ្សេងទៀតសម្រាប់ប្រើប្រាស់ ឬក៏មានក្នុងទំហំដ៏តិចតួច។ ក្រោយមកទៀត ការបែងចែកផលប្រយោជន៍ និងតម្លៃវិភាគទាន (ធនធានព្រៃឈើ និងចំណូល) បានក្លាយជាបញ្ហាសំខាន់មួយ ស្របពេលដែលការលើកកម្ពស់ជីវភាពបានក្លាយជាគោលដៅគ្រប់គ្រងសហគមន៍ បន្ថែមលើការស្ដារព្រៃឈើឡើងវិញ។ នៅឆ្នាំ២០០៩ គោលការណ៍ណែនាំពីសហគមន៍ព្រៃឈើបានតម្រូវឲ្យសមាជិកសហគមន៍ ចូលរួមវិភាគទានប្រាក់ចំណូលរបស់ពួកគេ ៣៥% សម្រាប់សកម្មភាពកាត់បន្ថយភាពក្រីក្រក្នុសហគមន៍ ដែលនេះបានឆ្លុះបញ្ចាំងយ៉ាងច្បាស់ពីសមធម៌ក្នុងការកាត់បន្ថយភាពក្រីក្រ។ ជាទូទៅសមាជិកទាំងអស់មានសិទ្ធិ និងការទទួលខុសត្រូវស្មើគ្នា តែជាក់ស្ដែងមានសមាជិកខ្លះ មិនត្រូវការប្រើប្រាស់ធនធាន ហើយខ្លះទៀតមិនមានលទ្ធភាព ឬពេលវេលាចូលទៅប្រមូលធនធានដែលជាចំណែករបស់ពួកគេទេ ដូចនេះសមាជិកទាំងអស់មិនទទួលបានផលប្រយោជន៍ប្រកបដោយសមធម៌នោះទេ។ ឧទាហរណ៍៖ គ្រួសារសមាជិកដែលក្រីក្រខ្លាំង ភាគច្រើនគ្មានលទ្ធភាព និងមធ្យោបាយសម្រាប់ដកហូត និងដឹកជញ្ជូនផលព្រៃឈើជាចំណែកដែលពួកគេត្រូវទទួលបានពីសហគមន៍នោះទេ។ ដើម្បីឆ្លើយតបនឹងបញ្ហាវិសមធម៌តាមបរិបទនេះ សហគមន៍ព្រៃឈើខ្លះបានលក់ផលឈើ របស់ពួកគេជាសហគមន៍ហើយបែងចែកប្រាក់ចំណូលក្នុងចំណោមសមាជិក នៅពេលដែលសហគមន៍ខ្លះទៀតបានកែសម្រួលផែនការគ្រប់គ្រង ដើម្បីអនុញ្ញាតិឲ្យសមាជិកប្រមូលផលដែលពួកគេត្រូវការដូចជា អុស និងអនុផលព្រៃឈើផ្សេងទៀត។

ឧទាហរណ៍មួយទៀតនៃបញ្ហាសមធម៌តាមបរិបទគឺ មានគ្រួសារសមាជិកក្រីក្រមួយចំនួនមិនអាចប្រើប្រាស់ផលប្រយោជន៍សាធារណៈក្នុងសហគមន៍ ដូចជាសាលារៀនបានទេ ដោយសារពួកគេគ្មានលទ្ធភាពរ៉ាប់រងការចំណាយថ្លៃសាលា ឬការទិញឯកសណ្ឋានសម្រាប់កូនរៀនជាដើម។

ជាលទ្ធផលមានគម្រោងជាច្រើនបានប្ដូរមកយកចិត្តទុកដាក់ពង្រឹងសមធម៌នៃការបែងចែក កាត់បន្ថយបញ្ហាវិសមធម៌តាមបរិបទ និងលើកកម្ពស់សមធម៌តាមនីតិវិធី ក្នុងចំណោមសមាជិកសហគមន៍ព្រៃឈើ។ ប្រការនេះបានទាមទារឲ្យមានតំណាងជាស្ត្រី និងក្រុមដែលងាយរងគ្រោះ (ដូចជា ក្រុមជនជាតិភាគតិច) ចូលរួមជាសមាជិកគណៈកម្មការគ្រប់គ្រងសហគមន៍ ព្រមទាំងមានអភ័យឯកសិទ្ធិក្នុងការសម្រេចចិត្តមួយចំនួនលើការគ្រប់គ្រងសហគមន៍។ ជាងនេះទៀតការយកចិត្តទុកដាក់លើអភិបាលកិច្ចល្អ (កំណត់អត្តសញ្ញាណសមាជិកក្រីក្រ និងងាយរងគ្រោះរួមមានស្ត្រី តាមរយៈការធ្វើចំណាត់ថ្នាក់ទ្រព្យធន និងស្ថិតិភាពក្រីក្រ) ជាបន្តបន្ទាប់បានឈានដល់ដំណើរការធ្វើសេចក្ដីសម្រេចចិត្តមួយដែលឆ្លើយតបនឹងតម្រូវការរបស់សមាជិសហគមន៍ដែលងាយរងគ្រោះ។

*ដកស្រង់ពីឯកសារ Mc Dermott M.H. and Schreckenberg K., 2009. Equity in community forestry: insights from North and South. International Forestry Review, 11(2), pp. 157-170.*

# ស.៤

## តើបញ្ហាសមធម៌សំខាន់ៗមានអ្វីខ្លះ នៅក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុតាមរយៈព្រៃឈើ?

ជាទូទៅគោលការណ៍គ្រឹះ និងគុណតំលៃនៃការលើកកម្ពស់សមធម៌ក្នុងវិស័យព្រៃឈើ ដូចគ្នានឹងក្នុងយន្តការរេដបូកដែរ។ ទិដ្ឋភាពសមធម៌ទាំងបី មានសារសំខាន់ណាស់ដើម្បីឲ្យរេដបូកទទួលជោគជ័យ ដូចដែលបានចែងក្នុងកិច្ចព្រមព្រៀងទីក្រុងកាន់គូន[2]។ កិច្ចព្រមព្រៀងនេះបានចែងថា សមធម៌មានសារសំខាន់ក្នុងការធានាឲ្យបាននូវ ភាពស្របច្បាប់ និងប្រសិទ្ធិភាពនៃយន្តការរេដបូក ក្នុងការបែងចែកផលប្រយោជន៍ និងតំលៃវិភាគទាន និងការចូលរួមដោយស្មើភាពក្នុងការធ្វើសេចក្ដីសម្រេចចិត្ត ក៏ដូចជាការទទួលបានផលប្រយោជន៍ពីកាបោន និងផលប្រយោជន៍ផ្សេងទៀត (Chhatre et al., 20123[3]; McDermott et al., 2012[4])។

ការជជែកវែកញែកពីសមធម៌នៃរេដបូកនាពេលថ្មីៗនេះផ្ដោតលើសមធម៌នៅកម្រិតអន្តរជាតិ ដែលខុសពី បញ្ហាសមធម៌នៅថ្នាក់ជាតិ និងនៅសហគមន៍។ សមធម៌នៅថ្នាក់អន្តរជាតិនេះសំដៅលើការទទួលខុសត្រូវរបស់ ប្រទេសអភិវឌ្ឍន៍ (ប្រទេសឧស្សាហកម្ម) ក្នុងការបញ្ចេញឧស្ម័ន ដែលមានកាតព្វកិច្ចផ្ដល់ធនធានហិរញ្ញវត្ថុដល់ប្រទេសកំពុងអភិវឌ្ឍ (ប្រទេសដែលមានព្រៃឈើ) ឲ្យថែរក្សាព្រៃឈើដើម្បីកាត់បន្ថយការសាយភាយឧស្ម័ន។ ប៉ុន្តែនៅពេលដែលចំណេះដឹងពីរេដបូកបានកើនឡើង បញ្ហាសមធម៌នៃរេដបូកត្រូវបានជជែកពិភាក្សានៅក្នុងគ្រប់កម្រិត (សូមអានប្រអប់ទី២)។

បញ្ហាសមធម៌នៃរេដបូក នៅថ្នាក់សហគមន៍ ក៏មិនខុសពីសមធម៌នៅក្នុងវិស័យព្រៃឈើដែរ។ បញ្ហាមួយចំនួនដែលមានឥទ្ធិពល ការចែករំលែកផលប្រយោជន៍ពីកាបោន និងផលប្រយោជន៍ផ្សេងទៀតនៃរេដបូករួមមាន ភាពមិនច្បាស់លាស់នៃកម្មសិទ្ធិលើធនធានព្រៃឈើភាពទន់ខ្សោយនៃអភិបាលកិច្ចមូលដ្ឋាន ការឆ្លៀតចាប់យកផលប្រយោជន៍ពីសំណាក់ក្រុមអ្នកមានឥទ្ធិពលក្នុងសហគមន៍ និងការមិនឲ្យសមាជិកសហគមន៍ដែលងាយរងគ្រោះដូចជាស្ត្រី និងកុមារចូលរួមក្នុងដំណើរការសម្រេចចិត្ត។ មូលហេតុដែលធ្វើឲ្យបាត់បង់ និងរេចរឹលព្រៃឈើមានលក្ខណៈខុសៗគ្នាតាមបរិបទនីមួយៗ ហើយបណ្ដាលពីកត្តាខាងក្រៅពីវិស័យព្រៃឈើ ដែលទាំង

---

[2] ដកស្រង់ពីសន្និសិទ្ធិស្ដីពីការប្រែប្រួលអាកាសធាតុនៃអង្គការសហប្រជាជាតិទីក្រុងកាន់គូន ប្រទេសម៉ិចស៊ិច ថ្ងៃទី២៩ វិច្ឆិកា ២០១០។

[3] Chhatre, A., Lakhanpal, S., Larson, A. M., Nelson, F.,Ojha, H. and Rao, J., 2012. Social safeguards and co-benefits in REDD+: a review of the adjacent possible. *Current Opinion in Environmental Sustainability* 4, pp. 654-660. Available at: http://dx.doi.org/10.1016/j.cosust.2012.08.006

[4] McDermott, C.L., Coad, L., Helfgott, A., and Schroeder, H., 2012. Operationalizing social safeguards in REDD+: actors, interests and ideas. *Environmental Science & Policy* 21, pp. 63-72. Available at: http://dx.doi.org/10.1016/j.envsci.2012.02.007



នេះក៏អាចជះឥទ្ធិលើបញ្ហាសមធម៌ក្នុងរេដបូកផងដែរ។ តាមរយៈការវិវត្តន៍នៃការជជែកពិភាក្សាថ្មីៗនេះរេដបូក បានក្លាយជាយន្តការដែលផ្តោតការយកចិត្តទុកដាក់លើ គ្រប់កម្រិត អ្នកពាក់ព័ន្ធចម្រុះ និងគោលបំណងចម្រុះ។ ប្រការនេះបានបន្ថែមភាពស្មុគស្មាញដល់ដំណើរការធ្វើសេចក្តីសម្រេចចិត្ត ដោយសារត្រូវរួមបញ្ចូលនូវគំនិត និងចំណាប់អារម្មណ៍ខុសៗគ្នារបស់អ្នកពាក់ព័ន្ធទាំងនោះ ដែលជាឧបសគ្គដល់ការសម្រេចបានសមធម៌។

ប្រអប់ទី២៖ ការជជែកវែកញែកពីសមធម៌កនៃរេដបូក

នៅក្នុងរបាយការណ៍ពិភាក្សាពីបញ្ហាសមធម៌នៃរេដបូក ចងក្រងដោយ Di Gregorio et al. (2013) បានសង្កេតឃើញថា អ្នកពាក់ព័ន្ធនៅថ្នាក់ជាតិនៃប្រទេសឥណ្ឌូនេស៊ី និងប្រេស៊ីល បានពិភាក្សាពីការ បែងចែកកាតព្វកិច្ចក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័ន និងការទទួលខុសត្រូវលើហិរញ្ញប្បទានរេដបូក (សមធម៌នៃការបែងចែក) រវាងប្រទេសអភិវឌ្ឍ និងប្រទេសកំពុងអភិវឌ្ឍ ដែលរបាយការណ៍នេះបានធ្វើការឆ្លុះបញ្ចាំងពីបញ្ហាសមធម៌នៅថ្នាក់អន្តរជាតិ។ ដោយឡែក អង្គការក្រៅរដ្ឋាភិបាលមួយនៅក្នុងប្រទេសហ្វីលីពីន  បានយកចិត្តទុកដាក់ លើការចែករំលែកផលប្រយោជន៍ និងតំលៃវិភាគទាននៃ រេដបូកនៅក្នុងសហគមន៍។ ដូចគ្នាដែរអ្នកពាក់ព័ន្ធនៅក្នុងប្រទេសវៀតណាម បានផ្តោតការពិភាក្សារបស់ពួកគេ លើបញ្ហាសមធម៌នៃ រេដបូក នៅថ្នាក់មូលដ្ឋានហើយផ្សារភ្ជាប់ទៅនឹងការចិញ្ចឹមជីវិតរបស់ប្រជាសហគមន៍។ អង្គការក្រៅរដ្ឋាភិបាលនៅក្នុងប្រទេសនេះបានលើកឡើងពីកង្វល់របស់ពួកគេលើបញ្ហាសមធម៌ ដែលពាក់ព័ន្ធនឹងកម្មសិទ្ធិ ធនធាន និងសិទ្ធិជនជាតិដើម ដោយទាមទារឲ្យមានការទទួលស្គាល់សិទ្ធិសហគមន៍ ព្រមទាំងលើកកម្ពស់ការចូលរួមរបស់សហគមន៍ក្នុងការរៀបចំ និងអនុវត្តន៍រេដបូក។

*ប្រភព៖ Di Gregorio, M., Brockaus, M., Cronin, T., Muharrom, E., Santoso, L., Mardian, S. and Büdenbender, M. 2013. Equity and REDD+ in media: a comparative analysis of policy* discourse. Ecology and Society, 18(2).



# ស.៥

## តើអ្នកពាក់ព័ន្ធនៅមូលដ្ឋានអាចរងឥទ្ធិពលអ្វីខ្លះពីការកាត់បន្ថយការប្រែប្រួលអាកាធាតុតាមរយៈព្រៃឈើ ប្រសិនបើគ្មានសមធម៌?

រដ្ឋាភិបាល និងអង្គការនានាដែលចូលរួមក្នុងការពិភាក្សាពីរេដបូក ជឿជាក់ថាយន្តការនេះមិនត្រឹមតែជួយកាត់បន្ថយការបញ្ចេញឧស្ម័ន និងកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុប៉ុណ្ណោះទេ ថែមទាំងផ្តល់ប្រយោជន៍ជាច្រើនទៀតដល់សហគមន៍។

ប្រសិនបើអនុវត្តន៍បានត្រឹមត្រូវ រេដបូកនឹងជួយធ្វើឲ្យប្រសើរឡើងនូវសមធម៌នៅក្នុងអភិបាលកិច្ចព្រៃឈើទាំងថ្នាក់ជាតិ និងក្នុងសហគមន៍។ ផ្ទុយទៅវិញបើខ្វះទិដ្ឋភាពសមធម៌ណាមួយក្នុងការអនុវត្តរេដបូក វានឹងរាំងជោគជ័យនៃយន្តការនេះ ព្រមទាំងប៉ះពាល់ដល់ក្រុមអ្នកក្រ និងក្រុមងាយរងគ្រោះក្នុងសហគមន៍។ ប្រសិនបើគ្មានភាពជាតំណាង និងការចូលរួមដោយសកម្មពីអ្នកពាក់ព័ន្ធទាំងអស់ក្នុងយន្តការរេដបូក ក្រុមអ្នកមានឥទ្ធិពលក្នុងសហគមន៍អាចនឹងប្រើឥទ្ធិពលដើម្បីឆ្លៀតឱកាសទាញយកដីព្រៃ និងធនធានព្រៃឈើ ក៏ដូចជាផលប្រយោជន៍នានាពីយន្តការនេះផងដែរ។ ស្ថានភាពនេះនឹងបន្តរាំងសមាជិកសហគមន៍មួយចំនួនពីការទទួលបានផលប្រយោជន៍។ ភាពងាយរងគ្រោះរបស់ស្ត្រីជនជាតិដើម ភាគតិចការបាត់បង់ដីធ្លី របស់សមាជិសហគមន៍ នឹងរឹតតែធ្ងន់ធ្ងរ ប្រសិនបើពួកគេមិនបានចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត។ ការចូលរួម និងភាពជាតំណាងមានសារសំខាន់ណាស់សម្រាប់ក្រុមងាយរងគ្រោះទាំងនេះក្នុងការឆ្លើយតបនឹងភាពរើសអើងលើសិទ្ធិប្រើប្រាស់ដីរបស់ពួកគេ។ ជាងនេះទៀត កង្វះការទទួលបានធនធានព្រៃឈើ ព័ត៌មានទីផ្សារផលិតផលព្រៃឈើ និងប្រភពហិរញ្ញប្បទាន ព្រមទាំងកង្វះខាតជំនាញនិងលទ្ធភាពក្នុងការបញ្ចេញយោបល់ក្នុងការសម្រេចចិត្ត បានធ្វើឲ្យពួកគេកាន់តែមានភាពងាយរងគ្រោះធ្ងន់ធ្ងរថែមទៀត។

ជារួមប្រសិនបើទិដ្ឋភាពសមធម៌ (ការបែងចែក នីតិវិធី និងបរិបទ) មិនត្រូវបានបញ្ជ្រាបក្នុងការធ្វើសេចក្តីសម្រេចចិត្តលើ ការគ្រប់គ្រងព្រៃឈើ ការប្រែប្រួលអាកាសធាតុ និងរេដបូក ភាពងាយរងគ្រោះរបស់សហគមន៍មូលដ្ឋាន និងកាន់តែមានសភាពធ្ងន់ធ្ងរឡើង។




# ផ្នែកទី៣៖ ឯកសារគោលនយោបាយ និងភាពប្រឈម ក្នុងការលើកកម្ពស់សមធម៌នៅក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុតាមរយៈព្រៃឈើ នៅថ្នាក់មូលដ្ឋាន



# ស.៦

## តើមានក្របខ័ណ្ឌ និងគោលនយោបាយអន្តរជាតិអ្វីខ្លះដែលលើកកម្ពស់សមធម៌នៅក្នុងបរិបទនៃ ការប្រែប្រួលអាកាសធាតុ រេដបូក និងការគ្រប់គ្រងព្រៃឈើ ?

សមធម៌អាចត្រូវបានគិតគូរនៅថ្នាក់សហគមន៍ និងថ្នាក់ជាតិ ក៏ដូចជាពីជំនាន់មនុស្សមួយទៅមួយផងដែរ។ ទស្សនទានសមធម៌ ត្រូវបានបញ្ជ្រាប និងឆ្លុះបញ្ចាំងនៅក្នុងច្បាប់អន្តរជាតិនានា។ សេចក្តីថ្លែងការជាសាកលស្តីពីសិទ្ធិមនុស្សចែងថា ការទទួលស្គាល់នូវសេចក្តីថ្លៃថ្នូរ និងសិទ្ធិស្មើភាពគ្នាដោយមិនរើសអើងពូជសាសន៍ ជាមូលដ្ឋានគ្រឹះសម្រាប់ សេរីភាព យុត្តិធម៌ និងសន្តិភាពនៅក្នុងពិភពលោក (Weiss, 1990)[5]។

ពាក់ព័ន្ធនឹងបញ្ហាសមធម៌នៃរេដបូក សន្និសិទ្ធិ លើកទី១៥ (COP 15) នៃរដ្ឋជាភាគីអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ដែលបានធ្វើឡើងនៅទីក្រុង Copen-hagen ឆ្នាំ២០០៩ បានឈានដល់មតិរួមក្នុងការបង្កើតយន្តការ សម្រាប់ការពារផលប៉ះពាល់បរិស្ថាន និងសង្គមដល់សហគមន៍មូលដ្ឋានដែលពឹងអាស្រ័យលើព្រៃឈើ ព្រមទាំងដើម្បីបង្កើនផលប្រយោជន៍សម្រាប់ពួកគេប្រកបដោយសមធម៌។ គំនិតនេះត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការរៀបចំកិច្ចព្រមព្រៀងនៅក្នុងសន្និសីទលើកទី១៦ (COP16) នៅទីក្រុងកាន់គូន ដែលត្រូវបានឲ្យឈ្មោះថា កិច្ចព្រមព្រៀងកាន់គូន។ ដូចការបញ្ជាក់ពីខាងដើម កិច្ចព្រមព្រៀងនេះបានរួមបញ្ចូលនូវទិដ្ឋភាពទាំងបីនៃសមធម៌។ ឧបសម្ព័ន្ធទី១ នៃកិច្ចព្រមព្រៀងបានចែងពីគោលការណ៍ណែនាំ និងគោលនយោបាយស្តីពីការធានាសុវត្ថិភាព និងការលើកទឹកចិត្ត នៃយន្តការរេដបូក (សូមអានប្រអប់ទី៣)។ ការគោរពសិទ្ធិ និងចំណេះដឹងជនជាតិដើមភាគតិច និងសមាជិកសហគមន៍ទាំងអស់ ការចូលរួមដ៏ពេញលេញ និងមានប្រសិទ្ធិភាពរបស់អ្នកពាក់ព័ន្ធជាពិសេសជនជាតិដើម និងសហគមន៍មូលដ្ឋាន សុទ្ធសឹងជាកត្តាសំខាន់ ក្នុងការលើកកម្ពស់សមធម៌ នៅក្នុងបរិបទនៃ ការប្រែប្រួលអាកាសធាតុ រេដបូក និងការគ្រប់គ្រងព្រៃឈើ។

អនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច (UNDRIP) ដែលបានអនុម័តនៅឆ្នាំ ២០០៧ បានទទួលស្គាល់សិទ្ធិជនជាតិដើម លើបញ្ហាជាច្រើន និងបានផ្តល់ក្របខ័ណ្ឌការងារមួយសម្រាប់សហគមន៍អន្តរជាតិ ដែលមានដូចជា គោលការណ៍ សេរីភាពក្នុងការទទួលបានព័ត៌មាន និងការព្រមព្រៀងជាមុនជាដើម។ កិច្ចព្រមព្រៀងកាន់គូន ក៏បានលើកឡើងពីការគោរពអនុសញ្ញាសហប្រជាជាតិនេះដែរ

---

[5] Weiss, E.B., 1990. Our rights and obligations to future generations for the environment. *American Journal of International Law*, 84: pp. 198-207. Available at: http://dx.doi.org/10.2307/2203020



**ប្រអប់ទី៣៖ ការធានាសុវត្ថិភាពនៅក្នុង អនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ - កិច្ចព្រមព្រៀងកាន់គូន**

សមាជិកអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ បានយល់ស្របលើគោលការណ៍ចំនួន ៧ចំណុច ស្តីពីការធានាសុវត្ថិភាព រេដបូក នៅក្នុងសន្និសីទលើកទី១៦ (COP16) នៅទីក្រុងកាន់គូន ដែលមានឈ្មោះថា គោលការណ៍ធានាសុវត្ថិភាពកាន់គូន។ គោលការណ៍ទាំងនេះបានទទួលស្គាល់ហានិភ័យផ្នែកសង្គម និងបរិស្ថានបណ្តាលមកពីការអនុវត្តរេដបូក ក៏ដូចជាសារៈសំខាន់ក្នុងការធានាផលប្រយោជន៍ចម្រុះសម្រាប់សហគមន៍មូលដ្ឋាន។ យោងតាមគោលការណ៍ធានាសុវត្ថិភាពកាន់គូននេះ ការអនុវត្តយន្តការរេដបូក គួរយកចិត្តទុកដាក់លើចំណុចខាងក្រោម៖

1. សកម្មភាពរេដបូកត្រូវតែបំពេញបន្ថែម ឬក៏ស្របគ្នានឹងកម្មវិធីព្រៃឈើជាតិ ព្រមទាំងអនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិនានា
2. ប្រព័ន្ធអភិបាលកិច្ចព្រៃឈើជាតិ ត្រូវតែមានតម្លាភាព និងប្រសិទ្ធិភាព ដោយស្របតាមបទដ្ឋានច្បាប់ និងអធិបតេយ្យភាពជាតិនីមួយៗ
3. គោរពចំណេះដឹង និងសិទ្ធិ ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន ដោយស្របតាមកាតព្វកិច្ចអន្តរជាតិ ច្បាប់ និងបទដ្ឋានជាតិនានា និងអនុសញ្ញាសហប្រជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច ដែលបានអនុម័តដោយសមាជអង្គការសហប្រជាជាតិ
4. ការចូលរួមពេញលេញ និងប្រកបដោយប្រសិទ្ធិភាពរបស់អ្នកពាក់ព័ន្ធ ជាពិសេសជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាននៅក្នុងសកម្មភាពរេដបូក
5. សកម្មភាពរេដបូកត្រូវស្របនឹងគោលបំណងអភិរក្សព្រៃឈើ និងជីវចម្រុះ ប៉ុន្តែត្រូវប្រើប្រាស់ជាយន្តការ លើកទឹកចិត្តក្នុងកិច្ចប្រឹងប្រែងអភិរក្ស និងការពារព្រៃធម្មជាតិ និងប្រព័ន្ធអេកូស៊ីស្ទែម និងបង្កើនផលប្រយោជន៍សង្គម
6. សកម្មភាពដែលទប់ស្កាត់ការបាត់បង់ព្រៃឈើបន្ទាប់ពីការទូទាត់សំណងពីកាបោន
7. សកម្មភាពដើម្បីការពារ ការផ្លាស់ទីតាំងសហគមន៍ដោយបង្ខំ។

*ប្រភព៖ http://unfccc.int/resource/docs/2010/cop16/eng/07a01.pdf*



ដោយបានទទួលស្គាល់ ចំណេះដឹង និងសិទ្ធិជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន ក្នុងការពង្រឹងសមធម៌នៃរេដបូក។

ផ្តើមចេញពីកិច្ចព្រមព្រៀងកាន់គូននេះ ស្ថានប័នអន្តរជាតិ និងអង្គការនានាបានបង្កើតនូវគោលការណ៍ណែនាំ និងស្តង់ដារមួយចំនួននៃការធានាសុវត្ថិភាពបរិស្ថាន និងសង្គម។ គោលការណ៍ណែនាំទាំងនេះជាគោលការណ៍ស្ម័គ្រចិត្ត ដែលប្រទេសនីមួយៗអាចយកមកកែសម្រួល និងប្រើប្រាស់ស្របតាមបរិបទនៃប្រទេសរបស់ខ្លួន។ ភាគច្រើនគោលការណ៍ទាំងនេះពាក់ព័ន្ធនឹងសមាធាតុសមធម៌ដូចជា សេរីភាពនៃការទទួលបានព័ត៌មាន និងការយល់ព្រមជាមុន ការគោរពសិទ្ធិជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានអធិបតេយ្យភាពជាតិនីមួយៗ ការចែករំលែកផលប្រយោជន៍ប្រកបដោយសមធម៌ ការចូលរួមពេញលេញ និងប្រកបដោយប្រសិទ្ធិភាព ការទទួលបានព័ត៌មាន និងការពង្រឹងអំណាចដល់ក្រុមដែលមានភាពទន់ខ្សោយក្នុងសង្គម (រួមទាំងស្ត្រី) ចូលរួមក្នុងគម្រោងកាបោន ដែលស្របជាមួយអនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច។ គោលការណ៍ណែនាំទាំងនេះមាន៖

- ការប៉ាន់ប្រមាណយុទ្ធសាស្ត្រសង្គម និងបរិស្ថាន ដែលបង្កើតឡើងដោយមូលនិធិ Forest Carbon Partnership Facility ( www.forestcarbonpartnership.org/ )
- គោលការណ៍ក្របខ័ណ្ឌសង្គម និងបរិស្ថានសម្រាប់រេដបូក ដែលបង្កើតឡើងដោយ UNREDD ( www.un-redd.org )
- ស្តង់ដារខាងផ្នែកសង្គម និងបរិស្ថាន សម្រាប់រេដបូក ដែលបង្កើតឡើងដោយ Climate, Community, and Biodiversity Alliance ( www.redd-standards.org/ )
- ការធានាសុវត្ថិភាពសង្គម និងបរិស្ថានសម្រាប់រេដបូក បង្កើតឡើងដោយ Rainforest Alliance ( www.rainforest-alliance.org/publications/redd-safeguards-guide )

# ស.៧

## តើមានភាពប្រឈមអ្វីខ្លះក្នុងការធានាឲ្យមានសមធម៌ក្នុងការកាត់បន្ថយការប្រែប្រួលអាកាធាតុតាមរយៈព្រៃឈើ នៅថ្នាក់មូលដ្ឋាន ?

ការធ្វើឲ្យប្រសើរឡើង និងធានាបានសមធម៌ក្នុងការកាត់បន្ថយការប្រែប្រួលអាកាធាតុតាមរយៈព្រៃឈើ នៅថ្នាក់មូលដ្ឋាន ជាការងារដែលពិបាកមួយ។ ដោយសារសមធម៌ទាក់ទងនឹងកត្តាសង្គម ទស្សនទាននេះត្រូវបានឲ្យនិយមន័យខុសៗគ្នាទៅតាមបរិបទនីមួយៗ។ ម្យ៉ាងទៀត ភាពសមរម្យ (fairness) នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ និងរេដបូក ក៏មានន័យខុសៗគ្នាតាមស្ថានភាព និងវប្បធម៌សង្គមនីមួយៗដែរ។ នេះមានន័យថា ដើម្បីធ្វើឲ្យប្រសើរឡើងនូវបរិបទសម្រាប់សមធម៌វាមានសារសំខាន់ណាស់ក្នុងការស្វែងយល់នូវកត្តាសង្គម វប្បធម៌ និងជីវសាស្ត្រ។ ការវិភាគអំពីអ្នកណាជាអ្នកសម្រេចថា អ្វីដែលសមរម្យ និងមិនសមរម្យ និងនីតិវិធីក្នុងការសម្រេចនេះជាការសំខាន់ ដើម្បីស្វែងយល់ និងជ្រើសរើសទម្រង់សមធម៌សមស្របមួយ។

ទំនាក់ទំនង និងអន្តរកម្មអំណាចនៅថ្នាក់មូលដ្ឋាន ជាកត្តាមួយទៀតដែលមានឥទ្ធិពលលើសមធម៌។ អន្តរកម្ម និងទំនាក់ទំនងអំណាចមានឥទ្ធិពលលើដំណើរការដោយមានការចូលរួម និងការបែងចែកប្រកបដោយសមធម៌នូវ ធនធាន និងផលប្រយោជន៍នានា។ ការប្រើប្រាស់អំណាចអាចបង្កជាបញ្ហាដូចជា ការឆ្លៀតចាប់យកធនធានដោយក្រុមមានឥទ្ធិពលនៅក្នុងសហគមន៍ ភាពរើសអើងក្នុងការបែងចែកផលប្រយោជន៍ និងតំលៃវិភាគទាន នៃការប្រើប្រាស់ធនធានធម្មជាតិ។

ភាពប្រឈមមួយទៀតក្នុងការពង្រឹងសមធម៌នៃយន្តការរេដបូក និងការប្រែប្រួលអាកាសធាតុ គឺទាក់ទងនឹង កម្មសិទ្ធិដីធ្លី។ ភាពមិនច្បាស់លាស់លើកម្មសិទ្ធិលើដីធ្លី និងសិទ្ធិ និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធលើរេដបូក អាចនាំឲ្យមានការសម្រេចដកហូតសិទ្ធិប្រពៃណីនៃជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន។ ក្នុងករណីនេះ វាមានសារៈសំខាន់ណាស់ក្នុងការកំណត់ឲ្យបានច្បាស់លាស់ និងត្រឹមត្រូវនូវសិទ្ធិទទួលបានផលប្រយោជន៍ពីកាបោន និងសិទ្ធិផ្សេងៗទៀត ។ ភាពមិនច្បាស់លាស់ពី ការទទួលបានការប្រើប្រាស់ធនធាន និងភាពជាម្ចាស់ លើផលប្រយោជន៍ពីកាបោន និងផលប្រយោជន៍ផ្សេងទៀតក្នុងចំណោមអ្នកពាក់ព័ន្ធ អាចធ្វើឲ្យក្រុមដែលទន់ខ្សោយក្នុងសង្គម បាត់បង់ឱកាសចូលរួមធ្វើសេចក្ដីសម្រេចចិត្ត និងទទួលបានផលប្រយោជន៍ពីរេដបូក តាមអ្វីដែលពួកគេគួរតែទទួលបាន។

ការរៀបចំយន្តការបែងចែកផលប្រយោជន៍ និងតំលៃវិភាគទាន នៃរេដបូកជាបញ្ហាប្រឈមមួយទៀត។ ក្នុងស្ថានភាព ដែលផលប្រយោជន៍ពីរេដបូកនៅមានភាពស្រពិចស្រពិល ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានដែលបានការពារ និងគ្រប់គ្រងធនធានព្រៃឈើ និងប្រព័ន្ធអេកូស៊ីស្ទស៊ីនានាជាយូរមកហើយ នឹងមិនមានឆន្ទៈក្នុងចូលរួមកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នោះទេ។



ឧបសគ្គមួយទៀតគឺ ខ្វះភាពជាតំណាងនៃអ្នកពាក់ព័ន្ធនៅមូលដ្ឋានក្នុងការចរចារស្ដីពី ការប្រែប្រួលអាកាសធាតុ និងរេដបូក នៅលើឆាកអន្តរជាតិ។ នេះបណ្ដាលមកពីកម្រិតយល់ដឹងអ្នកពាក់ព័ន្ធនៅមូលដ្ឋាន និងតំណាងរបស់ពួកគេ ពីរេដបូក និងការប្រែប្រួលអាកាសធាតុ នៅទាបនៅឡើយ ដូចនេះពួកគេមិនអាចលើកឡើងពីកង្វល់ និងបញ្ហារបស់ពួកគេឲ្យបានក្បោះក្បាយទៅកាន់អ្នករៀបចំគោលនយោបាយ និងអ្នកធ្វើសេចក្ដីសម្រេចចិត្តបានដឹង។ ជាងនេះទៀតការខ្វះព័ត៌មានពីការប្រែប្រួលអាកាសធាតុ និងរេដបូកនៅថ្នាក់មូលដ្ឋាន បានរាំងពួកគេក្នុងការចូលរួមប្រកបដោយប្រសិទ្ធិភាពក្នុងដំណើរការធ្វើសេចក្ដីសម្រេចចិត្ត។ កត្តាទាំងនេះជាហានិភ័យដែលធ្វើឲ្យលទ្ធផលនៃការចរចារនេះ មិនឆ្លុះបញ្ចាំងពីត្រូវការសហគមន៍ ហើយថែមទាំងបង្កើននូវភាពងាយរងគ្រោះដល់ពួកគេពីសកម្មភាពមួយចំនួននៃគម្រោងរេដបូកទៀតផង។

ទាក់ទិននឹងបរិបទសង្គមវិញ វាមានសារៈសំខាន់ណាស់ក្នុងការទទួលស្គាល់ និងគោរព ចំណេះដឹងប្រពៃណីនៃសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ជាពិសេសក្នុងការឆ្លើយតបនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងរេដបូក។ ដោយសារការពិភាក្សាពីសមធម៌នៃរេដបូក ផ្ដោតលើបញ្ហាជនជាតិដើមភាគតិច និង សហគមន៍មូលដ្ឋាន វាជាការចាំបាច់ក្នុងការរៀនសូត្រពីបទពិសោធន៍ និងចំណេះដឹងរបស់ពួកគេ។ ប៉ុន្តែចំណុចនេះមិនទាន់ ត្រូវបានយកចិត្តទុកដាក់គ្រប់គ្រាន់នៅឡើយទេ ដែលបណ្ដាលឲ្យមានហានិភ័យខ្ពស់ដែលអាចនាំឲ្យបរាជ័យនៃយន្តការរេដបូក។




# ផ្នែកទី៤ ៖ ការអភិវឌ្ឍសមត្ថភាពដើម្បីលើកកម្ពស់សមធម៌នៅថ្នាក់មូលដ្ឋាន

# ស.៨

## តើអ្នកសម្របសម្រួលមូលដ្ឋានមានតួនាទីអ្វីខ្លះដើម្បីលើកកម្ពស់សមធម៌នៅក្នុងបរិបទនៃ ការប្រែប្រួលអាកាសធាតុ និងរេដបូក?

ការចូលរួម (Engagement) ជាដំណើរការនៃប្រមូលផ្តុំទស្សននានារបស់អ្នកចូលរួមបង្កើតជាគំនិតរួមមួយតាមរយៈ ការសំយោគ និងការសន្ទនា សម្រាប់អនុវត្តន៍សកម្មភាពរួមគ្នាដើម្បីឆ្លើយតបនឹងបញ្ហា និងកង្វល់រួម។

តាមរយៈនិយមន័យការចូលរួមខាងលើនេះ អ្នកសម្របសម្រួលសហគមន៍ត្រូវដើរតួនាទីចម្រុះដើម្បីដោះស្រាយបញ្ហា និងឧបសគ្គនានា ព្រមទាំងសម្របសម្រួលការចូលរួមរបស់អ្នកពាក់ព័ន្ធនៅមូលដ្ឋានដើម្បីលើកកម្ពស់ សមធម៌ក្នុងការងាររេដបូក និងការប្រែប្រួលអាកាសធាតុ។ តួនាទីមួយចំនួនរបស់អ្នកសម្របសម្រួលមានដូចខាងក្រោម៖

- អ្នករៀបចំសហគមន៍៖ ជួយសហគមន៍ដើម្បីត្រៀមខ្លួន ដូចជាការសម្របសម្រួល និងកំណត់គោលបំណងដើម្បីជួយដល់ក្រុមដែលទន់ខ្សោយក្នុងសង្គម
- អ្នកណែនាំដំណើរការ៖ រៀបចំដំណើរការដោយមានការចូលរួមក្នុងរយៈពេលវែង និងរយៈពេលខ្លី កំណត់គោលបំណងច្បាស់លាស់ នឹងធ្វើឲ្យប្រាកដថាជំហាននីមួយៗនៃដំណើរការទាំងមូល ជាប់ពាក់ព័ន្ធគ្នា ជាលក្ខណៈប្រព័ន្ធ
- អ្នកកសាងជំនឿចិត្ត៖ ជួយ/ផ្តល់អំណាចដល់ក្រុមទន់ខ្សោយ ដើម្បីឲ្យពួកគេមានភាពជឿជាក់ក្នុងការនិយាយ និងលើកឡើងពីបញ្ហាដែលពួកគេយល់ថាសំខាន់
- អ្នកផ្តល់ និងពន្យល់ព័ត៌មាន៖ មានចំណេះដឹងពីបច្ចុប្បន្នភាព ការវិវត្ត ស្តង់ដារ និងព័ត៌មានពីការប្រែប្រួលអាកាសធាតុ និងរេដបូក ព្រមទាំងមានសមត្ថភាពពន្យល់បកស្រាយព័ត៌មានទាំងនេះតាមបែបសាមញ្ញដោយមិនបញ្ចូលគំនិតខ្លួនឯង ដែលនាំឲ្យប៉ះពាល់ដល់ការយល់ឃើញរបស់អ្នកពាក់ព័ន្ធ
- អ្នកភ្ជាប់បណ្តាញ៖ មានសមត្ថភាពស្វែងយល់ពីភាពពាក់ព័ន្ធគ្នារវាងបញ្ហា និងស្ថានភាពក្រុមនានា ព្រមទាំង មានលទ្ធភាពជួយពួកគេក្នុងពេលដែលត្រូវការ
- អន្តរការីដែលអាចទុកចិត្តបាន៖ ជួយផ្សារភ្ជាប់សហគមន៍ និងអ្នកផលិត ទៅនឹងទីផ្សារ និងដំណើរការធ្វើសេចក្តីសម្រេចចិត្តដែលមានតម្លាភាព



- អ្នកបង្កឱកាសឲ្យមានការចូលរួម៖  ក្នុងការប្រមូល និងសំយោគគំនិតនានា អ្នកសម្របសម្រួលអាចស្វែងរកឱកាសដើម្បីជួយដល់អ្នកទន់ខ្សោយក្នុងសហគមន៍ បានបញ្ចេញសំលេងរបស់ពួកគេក្នុងការធ្វើសេចក្តីសម្រេចចិត្ត។
- អ្នកធ្វើកំណត់ត្រា៖ មានសមត្ថភាពកត់ត្រានូវរាល់ទស្សនយល់ឃើញក្នុងការពិភាក្សា និងចែករំលែកដល់អ្នក ដ៏ទៃដោយមិនផ្លាស់ប្តូរគំនិតដើម
- អ្នកដឹកនាំដែលគិតពីសមភាពយេនឌ័រ៖ មានសមត្ថភាពដោះស្រាយភាពប្រឈមចំពោះបញ្ហាយេនឌ័រដូចជា ភាពខុសគ្នារវាងអំណាច និងបែបបទសង្គម ព្រមទាំងជួយឲ្យបុរស និងស្ត្រីចូលរួមប្រកបដោយប្រសិទ្ធិភាព និងពេញលេញក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងការចែករំលែកផលប្រយោជន៍
- អ្នកគាំទ្រដល់ការសន្ទនារវាងអ្នកពាក់ព័ន្ធចម្រុះ៖ ប្រើប្រាស់វិធីសាស្ត្រនានា ក្នុងការសម្របសម្រួលការសន្ទនាក្នុងចំណោមអ្នកពាក់ព័ន្ធនានា ព្រមទាំងជួយឲ្យការពិភាក្សាឈានដល់ការយល់ឃើញរួមគ្នាមួយ
- អ្នកគាំទ្រការចូលរួមរបស់សហគមន៍៖  ធានា និងជម្រុញឲ្យមានការចូលរួមរបស់ជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋាន ក្នុងការសម្រេចចិត្តពីរដេបូក។



នៅក្នុងតួនាទីទាំងនេះ វាមានសារៈសំខាន់ណាស់ដែលអ្នកសម្របសម្រួលត្រូវរក្សាជំហររបស់ខ្លួនអព្យាក្រិត្យភាព ដើម្បីពង្រឹងសមធម៌។ នេះមានន័យថា អ្នកសម្របសម្រួលមិនត្រូវប្រកាន់យកជំហរណាមួយឡើយនៅក្នុងពេលសម្របសម្រួលការធ្វើសេចក្តីសម្រេចចិត្ត។ អ្នកពាក់ព័ន្ធនឹងសម្រេចថាអ្វីដែលមានសមធម៌សម្រាប់ពួកគេ ដោយផ្អែកលើបរិបទសង្គម វប្បធម៌ និងបរិស្ថានដែលពួកគេរស់នៅ។ ក្នុងការធ្វើឲ្យប្រសើរឡើងនូវសមធម៌តាមនីតិវិធី អ្នកសម្របសម្រួលត្រូវ ស្វែងយល់និងធានាថាក្រុមដែលទន់ខ្សោយក្នុងសហគមន៍ មានឱកាសបញ្ចេញយោបល់ពីចំណាប់អារម្មណ៍ និងក្តីកង្វល់របស់ពួកគេប្រកបដោយប្រសិទ្ធិភាព តាមរយៈការជម្រុញ និងជួយឲ្យពួកគេចូលរួមដោយសកម្ម។ទាក់ទងនឹងបញ្ហាសមធម៌តាមបរិបទ អ្នកសម្របសម្រួលត្រូវកំណត់ក្រុមទន់ខ្សោយក្នុងសហគមន៍ ដើម្បីជួយឲ្យពួកគេបានបញ្ចេញយោបល់ពីចំណាប់អារម្មណ៍របស់គេ ក្នុងការរៀបចំផែនការ និងអនុវត្តន៍គម្រោងរេដបូកតាមរយៈការកសាងសមត្ថភាព និងការជួយបង្កើនសិទ្ធិទទួលបានធនធាន និងផលប្រយោជន៍ពីកាបោន និងផលប្រយោជន៍ផ្សេងទៀត។

# ស.៩

## តើមានលក្ខណៈវិនិច្ឆ័យ និងសូចនាករ អ្វីខ្លះដើម្បីត្រួតពិនិត្យសមធម៌ នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ រេដបូក និងការគ្រប់គ្រងព្រៃឈើ ?

ដើម្បីធានាប្រសិទ្ធិភាពក្នុងការបញ្ជ្រាបគោលការណ៍ និងគុណតំលៃសមធម៌ក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ រេដបូក និងការគ្រប់គ្រងព្រៃឈើ ទាមទារឲ្យមានការត្រួតពិនិត្យលើទិដ្ឋភាពទាំងបីនៃសមធម៌។ លក្ខណៈវិនិច្ឆ័យ និងសូចនាករខាងក្រោមអាចជួយក្នុងការត្រួតពិនិត្យប្រសិទ្ធិភាពសមធម៌៖

សមធម៌នៃការបែងចែក៖ សមាសធាតុសំខាន់របស់សមធម៌នៃការបែងចែករួមមានការបែងចែកដោយស្មើភាព និងសមរម្យ នូងផលប្រយោជន៍ តំលៃវិភាគទាន និងហានិភ័យ ក្នុងចំណោមអ្នកពាក់ព័ន្ធ។ តារាងខាងក្រោមបង្ហាញពីសមាសធាតុសំខាន់នៃសមធម៌នៃការបែងចែក និងទិន្នន័យ បែបបរិមាណ និងបែបគុណភាពដែលត្រូវការដើម្បីត្រួតពិនិត្យការអនុវត្ត និងប្រសទ្ធិភាពនៃសមធម៌នៃការបែងចែកក្នុងរេដបូក៖

| សមាសធាតុ | ព័ត៌មាន ឬទិន្នន័យដែលត្រូវការសម្រាប់ត្រួតពិនិត្យ |
|---|---|
| តំលៃវិភាគទាន<br>( Cost ) | □ ប្រភេទនៃតំលៃវិភាគទាន៖ វិភាគទានជាសាច់ប្រាក់ និងមិនមែនសាច់ប្រាក់ដោយអ្នកពាក់ព័ន្ធតាមរយៈ កាចូលរួមកំលាំងពលកម្មក្នុងការងារគ្រប់គ្រងព្រៃឈើដូចជាការល្បាតព្រៃ ការដាំដុះឈើឡើងវិញ ការអនុវត្តបច្ចេកទេស រុក្ខវប្បកម្ម។ល។<br>□ ការបែងចែកការទទួលខុសត្រូវលើតំលៃវិភាគទាននេះ៖ អ្នកណាត្រូវរ៉ាប់រង ការចំណាយ ហើយត្រូវការចំណាយថវិកា និងពេលវេលាប៉ុន្មានសម្រាប់សម្មភាពគ្រប់គ្រងព្រៃឈើ ហើយត្រូវចំណាយនៅពេលណា |
| ហានិភ័យ | □ ការហាមឃាត់ការប្រើប្រាស់ធនធានព្រៃឈើ ភាពប្រឈមចំពោះការចិញ្ចឹមជីវិត ការមិនឲ្យឱកាសសមាជិកសហគមន៍មួយចំនួនចូលរួមក្នុងដំណើរការធ្វើសេចក្តី សម្រេចចិត្ត និងការចែករំលែកផលប្រយោជន៍ ការរំពឹងទុកដែលមិនអាចសម្រេចបានរបស់អ្នកពាក់ព័ន្ធនៅមូលដ្ឋាន និងការចំណាយខ្ពស់ជាងផលប្រយោជន៍ទទួលបាន |
| ផលប្រយោជន៍ | □ ផលប្រយោជន៍ជាសាច់ប្រាក់ និងផលប្រយោជន៍ផ្សេងទៀតពីព្រៃឈើ ដូចជា ប្រាក់ចំណូលពីកាបោន (បែងចែកជាបុគ្គល ឬសម្រាប់គម្រោងអភិវឌ្ឍសហគមន៍) និងផលប្រយោជន៍ផ្សេងទៀតពីព្រៃឈើ សកម្មភាពបង្កើនមុខរបរ និងប្រភពចំណូលផ្សេងៗ ការលើកម្ពស់ការចូលរួមរបស់ស្ត្រី និងក្រុមដែលទន់ខ្សោយក្នុងសហគមន៍ទៅក្នុងយន្តការរេដបូក<br>□ ករណីសិក្សាបង្ហាញពីការផ្លាស់ប្តូរ និងរបាយការណ៍នានាដែលបង្ហាញពី សិទ្ធិ និងផលប្រយោជន៍ |

**សមធម៌តាមនីតិវិធី៖** ជានាថាអ្នកពាក់ព័ន្ធទាំងអស់មានឱកាសចូលរួម និងបញ្ចេញយោបល់របស់ពួកគេក្នុងការធ្វើសេចក្ដីសម្រេចចិត្ត។ តារាងខាងក្រោមបង្ហាញពីសូចនាករ ក្នុងការត្រួតពិនិត្យសមធម៌តាមនីតិវិធី និងទិន្នន័យសម្រាប់វាស់វែងសូចនាករទាំងនេះ ។

| សមាសធាតុ | ព័ត៌មាន ឬទិន្នន័យដែលត្រូវការសម្រាប់ត្រួតពិនិត្យ |
|---|---|
| ការកំណត់អ្នកពាក់ព័ន្ធ និងស្ថាប័នសម្រេចចិត្ត នៅមូលដ្ឋាន | □ ការវិភាគអ្នកពាក់ព័ន្ធ<br>□ ស្ត្រី ជនជាតិដើមភាគតិច និងក្រុមដែលមានលទ្ធភាពទន់ខ្សោយ ត្រូវមានតំណាងចូលរួមក្នុងស្ថាប័នសម្រេចចិត្ត<br>□ ស្វែងយល់ពីបញ្ហាសមធម៌ ក៏ដូចជាកត្តាជម្រុញ និងឧបសគ្គនានា ក្នុងការចូលរួមរបស់អ្នកពាក់ព័ន្ធនីមួយៗ |
| ដំណើរការធ្វើសេចក្ដីសម្រេចចិត្ត | □ មានបទបញ្ញាផ្ទៃក្នុង និងលក្ខន្តិកៈសម្រាប់អនុវត្តន៍ពេលធ្វើសេចក្ដីសម្រេចចិត្តលើការគ្រប់គ្រង និងដកហូតធនធានព្រៃឈើ<br>□ ចំណេះដឹង និងបទពិសោធន៍ក្នុងការប្រើប្រាស់គោលការណ៍ សេរីភាពនៃការទទួលបានព័ត៌មាន និងការព្រមព្រៀងជាមុន ក្នុងការធ្វើសេចក្ដីសម្រេចចិត្តដោយមានការចូលរួម<br>□ បទបញ្ញាផ្ទៃក្នុង និងលក្ខន្តិកៈមានការបញ្ជ្រាបយេនឌ័រ និងការរួមបញ្ចូលគ្រប់ក្រុមនៅក្នុងសង្គម ទៅក្នុងយន្តការនៃការចម្រេចចិត្ត ការប្រើប្រាស់ធនធាន និងការចែករំលែកផលប្រយោជន៍<br>□ ស្ថាប័នសម្រេចចិត្តមានការប្រជុំជាញឹកញាប់ (ប៉ុន្មានដងក្នុងមួយខែ ឬឆ្នាំ) ហើយមានការកត់ត្រាកំណត់ហេតុត្រឹមត្រូវ<br>□ មានផែនការសកម្មភាពដើម្បីអនុវត្តន៍សេចក្ដីសម្រេចនៅក្នុងកិច្ចប្រជុំលើកមុន<br>□ មានយន្តការសំដែងមតិរិះគន់ ហើយសហគមន៍បានដឹងនិងអាចប្រើប្រាស់យន្តការនេះ |
| តម្លាភាព និងការទទួលបាន ព័ត៌មាន | □ ការទទួលបានព័ត៌មានស្ដីពីការគ្រប់គ្រងព្រៃឈើរួមមាន ព័ត៌មានពីមូលហេតុនៃការបាត់បង់ និងរេចរឹលព្រៃឈើ ប្រតិបត្តិការហិរញ្ញវត្ថុនៃសកម្មភាពគ្រប់គ្រងព្រៃឈើ ប្រភពថវិកា និងការចំណាយ និងយន្តការចែករំលែកផលប្រយោជន៍ (ប្រសិនបើមាន)<br>□ ព័ត៌មានពីហានិភ័យ ភាពប្រឈម និងតំលៃឱកាសនានា នៃយន្តការរេដបូក<br>□ វេទិកាអ្នកពាក់ព័ន្ធចម្រុះ ដែលកំពុងដំណើរការនៅក្នុង និងជុំវិញសហគមន៍ ដែលអាចប្រើប្រាស់ដើម្បីលើកកម្ពស់សមធម៌នៃរេដបូក<br>□ ចំណេះដឹងពីគម្រោង ឬសកម្មភាពអភិវឌ្ឍដីព្រៃឈើនានា ដែលអាចមានផលប៉ះពាល់ដល់ការរៀបចំ និងអនុវត្តគម្រោងរេដបូក |

សមធម៌តាមបរិបទ៖ តើស្ថានភាព សមត្ថភាព និងបរិយាកាសដែលមានស្រាប់ បានគាំទ្រដល់កត្តា សមធម៌នៃការបែងចែក   និងសមធម៌តាមនីតិវិធីដែរឬទេ។ ដូចនេះវាសំខាន់ណាស់ក្នុងការស្វែងយល់ពី គោលនយោបាយ ស្ថាប័ន និងដំណើរការនានា  កំពុងអនុវត្តន៍ លើការទទួលបានធនធាន តួនាទី និងការទទួលខុសត្រូវនៃអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងព្រៃឈើ ជាពិសេសរេដបូក។ ប៉ារ៉ាម៉ែត្រខាងក្រោមអាចប្រើប្រាស់ដើម្បីត្រួតពិនិត្យសមធម៌តាមបរិបទ៖

| សមាសធាតុ | ព័ត៌មាន ឬទិន្នន័យដែលត្រូវការសម្រាប់ត្រួតពិនិត្យ |
|---|---|
| បរិយាកាសនៃការគ្រប់គ្រងព្រៃឈើ | □ ស្ថាប័នគ្រប់គ្រងព្រៃឈើ ឧទាហរណ៍៖ អ្នកណាធ្វើសេចក្តីសម្រេចចិត្តក្នុងការគ្រប់គ្រងព្រៃឈើនាពេលកន្លងមក ហេតុអ្វីបានជាពួកគេជាអ្នកសម្រេចចិត្ត ហើយពួកគេសម្រេចចិត្តតាមរបៀបណា?<br>□ ឧបសគ្គរាំងដល់ការរួមបញ្ចូលគ្រប់ក្រុមក្នុងសង្គម ឧទាហរណ៍៖ កត្តាអ្វីខ្លះកំណត់ភាព ខុសគ្នាលើសិទ្ធិ ការទទួលបានធនធាន ឬការកាហាមឃាត់ ឧទាហរណ៍៖ ជនជាតិ យេនឌ័រ ឋានៈ ការអប់រំ និងអក្ខរកម្ម អាយុ មុខងារ ទីតាំង ស្ថានភាពគ្រួសារ សាសនា ភេទ ឧទាហរណ៍៖ តើកត្តាទាំងនេះប៉ះពាល់ដល់បញ្ហាសមធម៌របស់ក្រុមនីមួយៗបែបណា?<br>□ ទំនាស់ដែលបានកើតឡើងកន្លងមកលើការប្រើប្រាស់ដី និងផលិតផលព្រៃឈើ |
| សមត្ថភាពលើបញ្ហារេដបូក | □ កម្រិតចំណេះដឹងរបស់គណៈកម្មការ និងសមាជិកសហគមន៍លើគោលនយោបាយ និងច្បាប់ស្តីពីការទទួលបានធនធាន និងការគ្រប់គ្រងព្រៃឈើ<br>□ ចំណេះដឹងបច្ចុប្បន្នរបស់សមាជិកសហគមន៍ (ដូចជាស្រ្តី និង ជនជាតិដើមភាគតិច) ស្តីពីការគ្រប់គ្រងព្រៃឈើ ការប្រែប្រួលអាកាសធាតុ និងរេដបូក ក៏ដូចជាគោលនយោបាយ និងកម្មវិធីនានាដែលពាក់ព័ន្ធ<br>□ ការអភិវឌ្ឍសមត្ថភាពទាក់ទងនឹងការគ្រប់គ្រងព្រៃឈើ ការប្រែប្រួលអាកាសធាតុ និងរេដបូក ដែលគណៈកម្មការ និងសមាជិកសហគមន៍បានទទួល<br>□ វប្បធម៌ចែករំលែកចំណេះដឹងក្នុងចំណោមសមាជិកសហគមន៍ ដូចជាមានការ ផ្សព្វផ្សាយបន្តនូវចំណេះដឹងដោយសមាជិកសហគមន៍ដែលបានចូលរួមវគ្គ ទៅកាន់សមាជិកផ្សេងទៀត នៅក្នុងពេលប្រជុំសហគមន៍ |

[6] An organization, establishment, foundation, society, or the like, devoted to the promotion of a particular cause or program, especially one of a public, educational, or charitable character





# ស.១០

## តើរីខូហ្វ មានតួនាទីអ្វីខ្លះក្នុងការលើកកម្ពស់សមធម៌ក្នុងការកាត់បន្ថយការប្រែប្រួលអាកាធាតុតាមរយៈព្រៃឈើ ?

រីខូស - មជ្ឈមណ្ឌលសម្រាប់មនុស្ស និងព្រៃឈើ ទទួលស្គាល់ និងអនុវត្តន៍អភិក្រមដែលផ្អែកលើមូលដ្ឋានសិទ្ធិ ( right-based approach ) ដែលជាក្របខ័ណ្ឌការងារមួយរួមបញ្ចូលនូវបញ្ញាតិ គោលការណ៍ ស្តងដារ និងគោលដៅសិទ្ធិមនុស្សអន្តរជាតិ ទៅក្នុងការងារអភិវឌ្ឍន៍។ ក្នុងនាមជាស្ថាប័នបណ្តុះបណ្តាល រីខូហ្វ បានរៀបចំ ឯកសាបណ្តុះបណ្តាល និងសរសេរបាយការណ៍ស្រាវជ្រាវ ព្រមទាំងផ្តល់វគ្គបណ្តុះបណ្តាលស្តីពីទស្សនទាន និងគោលការណ៍សមធម៌សង្គម នៅក្នុងការកាត់បន្ថយ និងបន្សាំនឹងការប្រែប្រួលអាកាសធាតុដោយផ្អែកលើព្រៃឈើ។ ជាក់ស្តែងយើងមានគម្រោងថ្នាក់តំបន់ពីរដែលធ្វើការងារពង្រឹងសមធម៌នៅក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ គម្រោងទាំងពីរនោះគឺ គម្រោងកសាងសមត្ថភាពសហគមន៍ស្តីពីរេដបូក ក្រោមជំនួយថវិកាពី NORAD និងកម្មវិធី Green Mekong ដែលទទួលថវិកាពី USAID។ គម្រោងទាំងពីរបានបំពេញឲ្យគ្នាទៅវិញទៅមកទាំងផ្នែក តំបន់គោលដៅ វិធីសាស្រ្តអនុវត្តន៍ និងអ្នកទទួលផលពីគម្រោង។ គម្រោងទាំងពីរមានតំបន់គោលដៅរួមនៅក្នុងប្រទេសបីនៃតំបន់មេគង្គ ( ឡាវ ភូមា និងវៀតណាម )។ លើសពីនេះ គម្រោងកសាងសមត្ថភាពសហគមន៍ស្តីពីរេដបូកមានតំបន់គោលដៅបន្ថែម នៅប្រទេសនេប៉ាល់ និងឥណ្ឌូនេស៊ី ដោយឡែក កម្មវិធី Green Mekong មានតំបន់គោលដៅបន្ថែមនៅប្រទេសកម្ពុជា និងថៃ។ គម្រោងទាំងពីរនេះ បានប្រើប្រាស់វិធីសាស្រ្តបណ្តុះបណ្តាលសិក្ខាកាមដើម្បីឲ្យពួកគេអាចបណ្តុះបណ្តាលបន្តបាន។ គម្រោងកសាងសមត្ថភាពសហគមន៍ស្តីពីរេដបូក អនុវត្តន៍ថ្នាក់សហគមន៍ និងថ្នាក់ខេត្ត រីឯកម្មវិធី Green Mekong ផ្តោតលើថ្នាក់ខេត្ត និងថ្នាក់តំបន់។

ទាក់ទងនឹងក្រុមអ្នកទទួលផលពីគម្រោងវិញ កម្មវិធី Green Mekong ផ្តោតលើ មន្រ្តីរដ្ឋាភិបាលថ្នាក់ក្រោមជាតិ និងសង្គមស៊ីវិល ដែលធ្វើការជាមួយអ្នកពាក់ព័ន្ធនៅមូលដ្ឋាន រីឯគម្រោងកសាងសមត្ថភាពសហគមន៍ស្តីពីរេដបូក ផ្តោតលើ សហគមន៍ ស្ថាប័នរដ្ឋ និងអង្គការក្រៅរដ្ឋាភិបាល ថ្នាក់មូលដ្ឋាន ជាពិសេសស្រ្តី ជនជាតិដើមភាគតិច អ្នកសារព័ត៌មាន គ្រូបង្រៀន សិស្ស និងក្រុមយុវជន។ ការផ្សព្វផ្សាយបង្កើនចំណេះដឹង ការបណ្តុះបណ្តាល និងសកម្មភាពអភិវឌ្ឍសមត្ថភាព ជាការងារដែលគម្រោងកសាងសមត្ថភាពសហគមន៍ស្តីពីរេដបូកអនុវត្តន៍។ កម្មវិធី Green Mekong បានអនុវត្តន៍សកម្មភាពទាំងនេះនៅថ្នាក់ជាតិ និងថ្នាក់តំបន់ ទន្ទឹមនឹងការរួមចំណែកក្នុងការអភិវឌ្ឍគោលនយោបាយ ដោយសហការជាមួយស្ថាប័នរៀបចំគោលនយោបាយថ្នាក់តំបន់ដូចជា អាស៊ានជាដើម។ វិធានការគ្រប់ជ្រុងជ្រោយនេះមិនត្រឹមតែជួយអភិវឌ្ឍសមត្ថភាពដល់អ្នកពាក់ព័ន្ធនៅមូលដ្ឋាន ( គម្រោងកសាងសមត្ថភាពសហគមន៍ស្តីពីរេដបូក ) ប៉ុណ្ណោះទេ តែថែមទាំង ផ្សារភ្ជាប់បណ្តាញរវាងអ្នកពាក់ព័ន្ធនៅមូលដ្ឋាន និងអ្នករៀបចំ និងអនុវត្តន៍គោលនយោបាយ



នៅថ្នាក់ជាតិ និងថ្នាក់តំបន់ (កម្មវិធី Green Mekong)។ ដូចនេះគម្រោងទាំងពីរបានផ្តល់ជាកំលាំងចលកររួមក្នុងការពង្រឹងគោលការណ៍សមធម៌ នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ រេដបូក និងការគ្រប់គ្រងព្រៃឈើ នៅតំបន់អាស៊ី ប៉ាស៊ីហ្វិច។

មុនការបោះពុម្ពសៀវភៅសំណួរចំឡើយនេះ គម្រោងទាំងពីរបានសហការរៀបចំឯកសារបណ្តុះបណ្តាល ស្តីពីការលើកកម្ពស់សមធម៌សហគមន៍ នៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងព្រៃឈើ។ ដូចនេះការពន្យល់ខ្លីៗបែបសាមញ្ញលើទស្សនទានសមធម៌នៅក្នុងការប្រែប្រួលអាកាសធាតុ រេដបូក និងការគ្រប់គ្រងព្រៃឈើ ដែលមានក្នុងសៀវភៅនេះនឹងក្លាយជាឯកសារជំនួយស្មារតីបន្ថែមដ៏សំខាន់មួយសម្រាប់ឯកសារបណ្តុះបណ្តាលនេះ http://www.recoftc.org/training-manuals-and-guid es/improving-grassroots-equity-forests-and-climate-change-context-training។

សម្រាប់ព័ត៌មានបន្ថែមពីសមធម៌សូមចូលទៅកាន់៖

- សមធម៌នៅមូលដ្ឋាន៖ *http://www.recoftc.org/project/green-mekong/project/grassroots-equity-portal*
- វីដេអូពីសមធម៌យេនឌ័រ៖ *http://www.recoftc.org/project/green-mekong/videos/videowhat-gender-equity*
- សៀវភៅសំណួរចំឡើយពីសមធម៌យេនឌ័រ៖ *http://www.recoftc.org/project/grassroots-apacitybuilding-redd/q-and/gender-redd-qa-handbook*
- កម្មវិធី Green Mekong៖ *http://www.recoftc.org/project/green-mekong*
- គម្រោងកសាងសមត្ថភាពសហគមន៍ស្តីពីរេដបូក៖ *http://www.recoftc.org/project/grassroots-apacitybuilding-redd*





RECOFTC

THE CENTER FOR PEOPLE AND FORESTS

បេសកកម្មរបស់រីខូហ្វ គឺការពង្រឹងសមត្ថភាពរបស់ប្រជាជនមូលដ្ឋាន ដើម្បីទទួលបានសិទ្ធិរឹងមាំ លើកកម្ពស់អភិបាលកិច្ច និងការទទួលផលប្រយោជន៍ដោយសមធម៌ ពីការគ្រប់គ្រងប្រកបដោយនិរន្តរភាពនូវតំបន់ទេសភាពព្រៃឈើនៅអាស៊ី ប៉ាស៊ីហ្វិក។

រីខូហ្វ មានតួនាទីសំខាន់នៅក្នុងវិស័យព្រៃឈើ។ រីខូហ្វជាអង្គការអន្តរជាតិមិនស្វែងរកប្រាក់ចំណេញតែមួយគត់ដែល មានជំនាញក្នុងការអភិវឌ្ឍសមត្ថភាពសម្រាប់សហគមន៍ព្រៃឈើ។ រីខូហ្វធ្វើការងាររបស់ខ្លួនតាមរយៈយុទ្ធសាស្ត្រភ្ជាប់បណ្តាញការងារ និងការកសាងភាពជាដៃគូជាមួយស្ថាប័នរដ្ឋ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល វិស័យឯកជន ប្រជាជនមូលដ្ឋាន និងគ្រឹះស្ថានអប់រំ និងស្រាវជ្រាវ នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក និងតំបន់ដទៃទៀត។ រយៈពេលជាង ២៥ឆ្នាំ នៃបទពិសោធន៍ថ្នាក់អន្តរជាតិរបស់ខ្លួន រីខូហ្វបានរួមចំណែកស្វែងរកដំណោះស្រាយ នូវរាល់បញ្ហារវាងមនុស្ស និង ព្រៃឈើ ប្រកបដោយមានប្រសិទ្ធភាពតាមរយៈការ កសាងសមត្ថភាព ដោយរួមមានការសិក្សាស្រាវជ្រាវ និងការវិភាគការអនុវត្ត សាកល្បងសហគមន៍ព្រៃឈើ និងតាមរយៈការបណ្តុះបណ្តាល។

RECOFTC – The Center for People and Forests
P.O. Box 1111
Kasetsart Post Office
Bangkok 10903, Thailand
Tel (66-2) 940-5700
Fax (66-2) 561-4880
info@recoftc.org
www.recoftc.org

Printed on recycled paper